ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈយោគយល់

រវាង

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

និង

អង្គការសុខភាពគ្រួសារអន្តរជាតិ ( FHI 360 )

ស្តីពី

ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម

សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ខែកញ្ញា ឆ្នាំ២០២១

# អនុស្សរណៈយោគយល់

# រវាង

# លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

# និង

# អង្គការសុខភាពគ្រួសារអន្តរជាតិ ( FHI 360 )

# ស្តីពី

# ការអនុវត្តផែនការការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ផ្នែកទី១

## បុព្វកថា

"ដោយយល់ថា" លេខាធិការដ្ឋាន គ.ជ.អ.ប. មានបំណងអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល អន្តរជាតិ មានឈ្មោះថា អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ធ្វើសកម្មភាពចូលរួមចំណែក ដើម្បីការអភិវឌ្ឍសង្គម និងបម្រើផលប្រយោជន៍សាធារណៈ ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

"ដោយយល់ថា" អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) មានទីស្នាក់ការកណ្តាលនៅសហរដ្ឋអាមេរិក និងមានសាខាការិយាល័យកណ្តាលនៅក្នុងរាជធានីភ្នំពេញ ជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ធ្វើសកម្មភាពអាជីវកម្មមិនយកប្រាក់ចំណេញ ដូចមានចែងក្នុងខ្លឹមសារលក្ខន្តិកៈ នៃសេចក្តីប្រកាសរបស់អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ប្រចាំកម្ពុជានេះ។

"ដោយយល់ថា" អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ប្រចាំកម្ពុជាយល់ព្រមអនុវត្តតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងបទបញ្ញត្តិ លិខិតបទដ្ឋាននានា ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**ក្នុងគោលបំណង** នៃការចុះអនុស្សារណៈយោគយល់គ្នា រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) បានព្រមព្រៀងគ្នា ដូចមានចែងខាងក្រោម៖

## ផ្នែកទី២

## ខ្លឹមសារសំខាន់ៗនៃផែនការអនុវត្តគណនេយ្យភាពសង្គម

### ប្រការ ១.- ផែនការអនុវត្តការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០១៩-២០២៣)

ផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០១៩-២០២៣) បានរៀបចំឡើងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ក្រោមក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការងារគណនេយ្យភាពសង្គម គឺជាផ្នែកមួយដ៏សំខាន់នៃអភិបាលកិច្ចល្អ និងជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើរ នៃការចូលរួមរវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយការស្ថាបនា តាមរយៈការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ និងអនុវត្តសកម្មភាពនានា។ សកម្មភាពទាំងនោះ រួមបញ្ចូលសកម្មភាពដែលប្រជាពលរដ្ឋ និងតំណាងប្រជាពលរដ្ឋអាចធ្វើការផ្តល់យោបល់សម្រាប់ឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន និងត្រួតពិនិត្យតាមដានពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី និងអ្នកផ្តល់សេវា នៃសេវារដ្ឋបាលឃុំ សង្កាត់ សេវាអប់រំសិក្សា (សាលាបឋមសិក្សា) សេវាសុខាភិបាល (មណ្ឌលសុខភាព) និងសេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ក៏ដូចជាសេវាមួយចំនួនទៀតស្របទៅតាមការផ្ទេរមុខងារ និងធនធានទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ប្រការ ២.- គោលបំណង នៃអនុស្សារណៈយោគយល់ (MoU)

អនុស្សារណៈយោគយល់នេះ មានគោលបំណង ដើម្បីកំណត់ពីកាតព្វកិច្ច ការទទួលខុសត្រូវ និងផ្តល់កិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរគឺ លេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360) ដើម្បីអនុវត្តសកម្មភាពផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងតំបន់គោលដៅអនុវត្ត ដូចមានបញ្ជាក់

ក្នុងឧបសម្ព័ន្ធទី១ ព្រមទាំងផែនកាសកម្មភាព និងថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ និង ឧបសម្ព័ន្ធទី៣ នៃអនុស្សារណៈយោគយល់នេះ។

អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) នឹងខិតខំប្រឹងប្រែងស្វែងរកថវិកាគាំទ្រការអនុវត្ត ផែនការសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី១ ព្រម ទាំងរំពឹងថានឹងមានការពង្រីកតំបន់គោលដៅថ្មី និងសេវាថ្មីៗបន្ថែមទៀត ស្របតាមផែនការអនុវត្ត ការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់ កាលទី២ (២០១៩-២០២៣)។ តំបន់គោលដៅអនុវត្ត និងសេវាផ្សេងៗទៀតនឹងត្រូវបានធ្វើបច្ចុប្បន្ន ភាពជារៀងរាល់ឆ្នាំ ដោយផ្អែកលើការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ។

## ផ្នែកទី៣
## ភារកិច្ចរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.

**ប្រការ ៣.-**

ផ្តល់ការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងតំបន់គោលដៅ ស្តីពីខ្លឹមសារនៃអនុស្សារណៈយោគយល់នេះ។

**ប្រការ ៤.-**

ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាលឃុំ/សង្កាត់ មន្ត្រីជំនាញវិស័យសុខាភិបាល មន្ត្រីជំនាញវិស័យអប់រំ និងវិស័យផ្សេងៗទៀតតាមការកំណត់ជាក់ស្តែង នៅក្នុងតំបន់គោលដៅ អំពីទស្សនទាន ឧបករណ៍ និងដំណើរការនៃការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម ជាពិសេសគោលការណ៍អភិបាលកិច្ចល្អ និងខ្សែគណនេយ្យភាព ព្រមទាំងតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកតម្រូវការ ដើម្បីលើកកម្ពស់គោលការណ៍ខាងលើ និងគាំទ្រសម្របសម្រួលការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម នៅក្នុងតំបន់គោលដៅ។

**ប្រការ ៥.-**

គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់ផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) និងសៀវភៅណែនាំអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋក្នុងតំបន់គោលដៅ ដោយមានការណែនាំបច្ចេកទេស និង/ឬការតម្រង់ទិសអំពីរបៀបផលិតព័ត៌មាន ការដាក់តាំងបង្ហាញ ផ្សព្វផ្សាយ និងប្រើប្រាស់នៅក្នុងដំណើរការផែនការអនុវត្តគណនេយ្យភាពសង្គម (ផ.អ.គ.ស)។

**ប្រការ ៦.-**

សហការបណ្តុះបណ្តាលតម្រង់ទិស ដល់មន្ត្រីបង្គោលរបស់អង្គការដៃគូអនុវត្ត (NGOs) ស្តីពីផែនការអនុវត្តគណនេយ្យភាពសង្គម ដើម្បីឱ្យមានភាពស្របគ្នាជាមួយនឹងវគ្គបណ្តុះបណ្តាលបន្តដល់ដៃគូអនុវត្តរបស់ផ្នែកតម្រូវការ តាមបណ្តារដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌគោលដៅ។

**ប្រការ ៧.-**

ត្រួតពិនិត្យការអនុវត្តជាប្រចាំនូវការបំពេញការងារ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាឃុំ/សង្កាត់ មន្ត្រីជំនាញវិស័យសុខាភិបាល មន្ត្រីជំនាញវិស័យអប់រំ និងវិស័យផ្សេងទៀតតាមការកំណត់ជាក់ស្តែងដែលពាក់ព័ន្ធ ដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងដំណើការដាក់ពិន្ទុដោយផ្នែកទាំងពីរ (អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋ) ក្នុងដំណើរការអនុវត្តផែនការគណនេយ្យភាពសង្គម បានត្រឹមត្រូវពេញលេញ និងស្របតាមវដ្តនៃសកម្មភាព ផែនការអនុវត្តគណនេយ្យភាពសង្គមប្រចាំឆ្នាំ និងឯកសារណែនាំស្តីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់។

**ប្រការ ៨.-**

រៀបចំ និងចែករំលែកនូវរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តផែនការគណនេយ្យភាពសង្គមជាទៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដូចដែលបានឯកភាពគ្នាតាមមាតិកា នៃរបាយការណ៍ដែលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី៤។

**ប្រការ ៩.-**

សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ផ្នែកផ្គត់ផ្គង់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដំណើរការអនុវត្តការងារគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងតំបន់គោលដៅដែលបានកំណត់។

## ផ្នែកទី៤

## ភារកិច្ចរបស់អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)

**ប្រការ ១០.-**

អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ប្រកាន់គោលជំហរជាអព្យាក្រឹត្យចំពោះគណបក្សនយោបាយទាំងអស់ និងគោរពទាំងស្រុងនូវខ្លឹមសារច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងបទបញ្ញត្តិទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមិនអនុញ្ញាតឱ្យបុគ្គលិករបស់ខ្លួនចូលរួមក្នុងសកម្មភាពទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិភាព ស្ថិរភាព និងសន្តិសុខសណ្តាប់ធ្នាប់

សាធារណៈ ឬបង្កភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ជាតិ ប្រពៃណី សាសនា ទំនៀម ទំលាប់របស់សង្គមកម្ពុជា។

ចូលរួមអនុវត្តតែសកម្មភាពណា ដែលបានទទួលការអនុញ្ញាត ដើម្បីបម្រើសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈជនទូទៅ។ ធ្វើអាជីវកម្មមិនយកចំណេញ និងមិនចូលរួមរាល់គ្រប់សកម្មភាពនយោបាយនានា ដោយប្រកាន់ខ្ជាប់នូវទិសដៅមនុស្សធម៌ និងអភិវឌ្ឍន៍សង្គមជាតិ។

**ប្រការ ១១.-**

ផ្តល់ការណែនាំដល់បុគ្គលិករបស់អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះកិច្ចសន្យាជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ទាក់ទងនឹងខ្លឹមសារនៃអនុស្សារណៈយោគយល់នេះ។

**ប្រការ ១២.-**

ផ្តល់ការបណ្តុះបណ្តាលដល់អង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្ត ដែលបានចុះកិច្ចសន្យាជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) អំពីទស្សនៈទាន ផ្តល់ឧបករណ៍ នីតិវិធីដំណើរការនៃការងារគណនេយ្យភាពសង្គម គោលការណ៍អភិបាលកិច្ចល្អ ខ្សែគណនេយ្យភាព និងសារៈសំខាន់នៃការផ្សាភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើរក្នុងការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ដូចជាការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ ក្នុងដំណើរការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២។

**ប្រការ ១៣.-**

ផ្តល់ថវិកាគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្ត ដែលបានចុះកិច្ចសន្យាជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) សម្រាប់អនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម។

**ប្រការ ១៤.-**

ត្រួតពិនិត្យ តាមដាន វាយតម្លៃការអនុវត្តជាប្រចាំរបស់ខ្លួន និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្ត ដែលបានចុះកិច្ចសន្យាជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ដើម្បីធានាថាសកម្មភាពការងារគណនេយ្យភាពសង្គមបានអនុវត្តយ៉ាងត្រឹមត្រូវពេញលេញ ដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមផែនការអនុវត្តការងារគណនេយ្យភាពសង្គម និងឯកសារណែនាំបច្ចេកទេសកិច្ចប្រតិបត្តិស្តីពីការងារគណនេយ្យភាពសង្គមរបស់ផ្នែកតម្រូវការ។

**ប្រការ ១៥.-**

រៀបចំ និងចែករំលែកនូវអនុស្សារណៈយោគយល់ និងផែនការសកម្មភាពប្រចាំឆ្នាំ របស់អង្គការដៃគូអនុវត្តនានា ដែលបានចុះកិច្ចសន្យាអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម ជាមួយអង្គការ

សុខភាពគ្រួសារអន្តរជាតិ (FHI 360) ជូនដល់លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការសម្របសម្រួល និងកិច្ចសហការគាំទ្របច្ចេកទេសក្នុងការអនុវត្តសកម្មភាពនានារបស់អង្គការដៃគូអនុវត្តទាំងនោះ។

**ប្រការ ១៦.-**

រៀបចំ និងចែករំលែកផ្ញើនូវរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម ជារៀងរាល់ឆមាស និងប្រចាំឆ្នាំ ដូចដែលបានឯកភាពគ្នាតាមទម្រង់មាតិកា នៃរបាយការណ៍ដែលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី៤ ដើម្បីផ្ញើជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងអំឡុងពេល ៣០ (សាមសិបថ្ងៃ) បន្ទាប់ពីកាលបរិច្ឆេទ នៃប្រតិទិនប្រចាំឆ្នាំ។

**ប្រការ ១៧.-**

សហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃផ្នែកផ្គត់ផ្គង់ក្នុងដំណើរការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងតំបន់គោលដៅដែលបានកំណត់។

## ផ្នែកទី៥
## ការគាំទ្របច្ចេកទេស និងការចាត់ចែងសម្របសម្រួល

**ប្រការ ១៨.-**

ក្នុងករណីចាំបាច់ ភាគីទាំងពីរត្រូវរៀបចំកិច្ចប្រជុំសម្របសម្រួលបច្ចេកទេសលើដំណើរការអនុវត្តផែនការអនុវត្តការងារគណនេយ្យភាពសង្គម ក្នុងគោលបំណងដូចខាងក្រោម៖

- ពិនិត្យមើលអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៅក្នុងដំណើរការអនុវត្តសកម្មភាពផែនការអនុវត្តគណនេយ្យភាពសង្គម។
- កំណត់ពីបញ្ហាអាទិភាព និងស្វែងរកដំណោះស្រាយប្រកបដោយកិច្ចសហការគ្នា។
- ពិភាក្សា និងព្រមព្រៀងគ្នាលើចំណុចកែលម្អក្នុងដំណើរការអនុវត្តសកម្មភាព និងឧបករណ៍នានាដែលបានស្នើឡើងដោយភាគីទាំងពីរ។
- ពិភាក្សា និងព្រមព្រៀងគ្នាលើផែនការសកម្មភាពនានា ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអនុវត្តនាពេលអនាគត។
- ពិភាក្សាអំពីបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងការអនុវត្តការងារគណនេយ្យភាពសង្គម។

## ផ្នែកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ១៩.-**

នាយកប្រតិបត្តិ ឬតំណាងអង្គការ អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ឬតំណាងដែលត្រូវទទួលបានតែងតាំងជាផ្លូវការផ្សេងទៀតរបស់អង្គការនេះ ត្រូវបានទទួលស្គាល់ឱ្យធ្វើសកម្មភាពក្នុងនាមអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រោយពេលចុះហត្ថលេខាលើអនុស្សារណៈនេះ។

**ប្រការ ២០.-**

អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) អាចផ្អាកសកម្មភាពរបស់ខ្លួនបានដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកលេខាធិការដ្ឋាន គ.ជ.អ.ប. ឱ្យបានមុនយ៉ាងតិច ៦០(ហុកសិប) ថ្ងៃ មុនផ្អាកសកម្មភាពរបស់អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) និងត្រូវធ្វើរបាយការណ៍បូកសរុបការងារ និងរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងប្រការ១៥ នៃអនុស្សារណៈនេះ។

**ប្រការ ២១.-**

លេខាធិការដ្ឋាន គ.ជ.អ.ប. អាចបញ្ចប់សុពលភាពអនុស្សារណៈនេះបាន ក្នុងករណីដែលអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) អនុវត្តមិនបានត្រឹមត្រូវស្របតាមខ្លឹមសារអនុស្សារណៈ ឬក្នុងករណីអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ធ្វើសកម្មភាពប៉ះពាល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ជាតិ សាសនា ទំនៀមទំលាប់ប្រពៃណីរបស់សង្គម នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២២.-**

ក្នុងករណីអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) មិនបានអនុវត្តតាមប្រការ១០ និងប្រការ១៥ នៃអនុស្សារណៈនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ដើម្បីសុំឲ្យអនុវត្តតាមប្រការទាំងពីរនេះ។ ក្នុងករណីមិនបានអនុវត្ត លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃបន្ថែមទៀត។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន លេខាធិការដ្ឋាន គ.ជ.អ.ប. សម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សារណៈនេះ។

**ប្រការ ២៣.-**

អនុស្សារណៈនេះអាចបញ្ចប់បានដោយភាគីណាមួយ បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ ផ្ញើជូនទៅភាគីម្ខាងទៀត។

**ប្រការ ២៤.-**

អនុស្សារណៈនេះចូលជាធរមានចាប់អនុវត្តពីថ្ងៃចុះហត្ថលេខាដោយភាគីទាំងពីរ និងមានសុពលភាព ចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់ដំណាច់ឆ្នាំ២០២៣ ព្រមទាំងអាចបន្តសុពលភាពបាន ដោយមានការយល់ព្រមពីភាគីទាំងពីរ។ សុពលភាពនៃអនុស្សារណៈនេះ នឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិក្រោយថ្ងៃផុតកំណត់។

អនុស្សារណៈនេះ អាចធ្វើវិសោធនកម្មនៅពេលណាមួយក្នុងករណី ដែលមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ។

ការសុំបន្តសុពលភាពអនុស្សារណៈនេះ ត្រូវធ្វើឡើងឱ្យបាន៦០(ហុកសិប)ថ្ងៃ មុនថ្ងៃផុតសុពលភាពអនុស្សារណៈ។

**ប្រការ ២៥.-**

អនុស្សារណៈនេះធ្វើឡើងជាពីរភាសាច្បាប់ដើម មានជាភាសាខ្មែរ និងជាភាសាអង់គ្លេស ដោយខ្លឹមសារអនុស្សារណៈនេះទាំងពីរមានតម្លៃអនុវត្តស្មើគ្នា ហើយភាគីទាំងពីរត្រូវតម្កល់រក្សាទុកប្រើប្រាស់ជាផ្លូវការរៀងៗខ្លួន។

| | **លេខាធិការដ្ឋាន គ.ជ.អ.ប.** | **អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)** |
|---|---|---|
| ហត្ថលេខា ៖ | | |
| ឈ្មោះ ៖ | ទ៉ាន់ ចំរើន | រស់ សុភាព |
| មុខងារ ៖ | ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. | តំណាងអង្គការ FHI360 កម្ពុជា |
| កាលបរិច្ឆេទ ៖ | 21 - 09 - 2021 | 21 - 09 - 2021 |

## ភ្ជាប់ជូនឧបសម្ព័ន្ធទី១-ក៖

តំបន់គោលដៅសម្រាប់អនុវត្តក្នុងឆ្នាំ២០២២ អង្គភាពផ្តល់ដែលកំណត់ក្នុងអនុស្សារណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360)

| ល.រ | រាជធានី ខេត្ត | ក្រុង / ខណ្ឌ | ចំនួន រដ្ឋបាលសង្កាត់ | | ចំនួន សាលាបឋមសិក្សា | | ចំនួន មណ្ឌលសុខភាព | | អង្គការដៃគូអនុវត្ត ដែលបានចុះ MoU | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|
| | | | សង្កាត់ សរុប | សង្កាត់ អនុវត្ត | សាលាបឋម សរុប | សាលាបឋម អនុវត្ត | មណ្ឌល សរុប | មណ្ឌសុខភាព អនុវត្ត | | |
| ១ | បន្ទាយមានជ័យ | សិរីសោភ័ណ្ឌ | ៧ | ៧ | ២៩ | ១៤ | ៨ | ៨ | ភ្នំស្រីដើម្បីអភិវឌ្ឍន៍ (PSOD) | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) |
| | | ប៉ោយប៉ែត | ៣ | ៣ | ៣៨ | ៦ | ៤ | ៤ | | |
| | សរុប | ២ | ១០ | ១០ | ៦៧ | ២០ | ១២ | ១២ | | |
| ២ | សៀមរាប | សៀមរាប | ១២ | ១២ | ៥២ | ២៤ | ១១ | ១១ | សម្ព័ន្ធសុខភាពកុមារនិងសុខភាពបន្តពូជ (RACHA) | |
| | សរុប | ១ | ១២ | ១២ | ៥២ | ២៤ | ១១ | ១១ | | |
| ៣ | បាត់ដំបង | បាត់ដំបង | ១០ | ១០ | ៣៦ | ២០ | ៧ | ៧ | អង្គការអមរា (Amara) | |
| | សរុប | ១ | ១០ | ១០ | ៣៦ | ២០ | ៧ | ៧ | | |
| ៤ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | ៤ | ៤ | ៨ | ៨ | ២ | ២ | អង្គការស្តារកម្ពុជា (Star Kampuchea) | |
| | សរុប | ១ | ៤ | ៤ | ៨ | ៨ | ២ | ២ | | |
| ៥ | កណ្តាល | តាខ្មៅ | ១០ | ១០ | ២៦ | ២៤ | ៥ | ៥ | វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ (API) | |
| | សរុប | ១ | ១០ | ១០ | ២៦ | ២៤ | ៥ | ៥ | | |
| ៦ | កំពត | កំពត | ៥ | ៥ | ១២ | ១២ | ៣ | ៣ | ភាពជាដៃគូសង្គមស៊ីវិលកម្ពុជា(CCSP) | |
| | សរុប | ១ | ៥ | ៥ | ១២ | ១២ | ៣ | ៣ | | |
| ៧ | រាជធានីភ្នំពេញ | ច្បារអំពៅ | ៨ | ៨ | ២០ | ២០ | ៨ | ៨ | អង្គការដៃគូ ក្រុមប្រឹក្សាយុវជនកម្ពុជា Youth Council of Cambodia (YCC) | តំបន់គោលដៅគ្រោងស្នើសុំពង្រីក អនុវត្ត |
| | | ព្រែកព្នៅ | ៥ | ៥ | ១៣ | ១៣ | ៥ | ៥ | | |
| | សរុប | ២ | ១៣ | ១៣ | ៣៣ | ៣៣ | ១៣ | ១៣ | | |
| | សរុបរួម | ៩ | ៦៤ | ៦៤ | ២២០ | ១៤១ | ៥៣ | ៥៣ | ៧ អង្គការដៃគូអនុវត្ត | |

| គោលដៅអនុវត្តគណនេយ្យភាពសង្គមនៅសេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ | | | | | |
|---|---|---|---|---|---|
| ១ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | អង្គការស្តារកម្ពុជា (Star Kampuchea) | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) |
| ២ | បាត់ដំបង | បាត់ដំបង | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | អង្គការអមរា (Amara) | |
| ៣ | កំពត | កំពត | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | ភាពជាដៃគូសង្គមស៊ីវិលកម្ពុជា(CCSP) | |

*__បញ្ជាក់៖__ តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០២២ ខាងលើនេះអាចនឹងមានការប្រែប្រួលក្នុងករណីមានការធ្វើបច្ចុប្បន្នភាពតំបន់គោលដៅអនុវត្ត នៅឆ្នាំបន្តបន្ទាប់ ដោយស្រប តាមការពិភាក្សា និងឯកភាពគ្នារវាងភាគីទាំងពីរ។*

*ការអនុវត្តគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង នឹងចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០២២នៅបីក្រុងគោលដៅគឺកំពង់ឆ្នាំង បាត់ដំបង និងកំពត។*

## ភ្ជាប់ជូនឧបសម្ព័ន្ធទី១-ខ៖

តំបន់គោលដៅសម្រាប់អនុវត្តក្នុងឆ្នាំ២០២៣ អង្គភាពផ្តល់ដែលកំណត់ក្នុងអនុស្សារណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360)

| ល.រ | រាជធានី ខេត្ត | ក្រុង / ខណ្ឌ | ចំនួន រដ្ឋបាលសង្កាត់ | | ចំនួន សាលាបឋមសិក្សា | | ចំនួន មណ្ឌលសុខភាព | | អង្គការដៃគូអនុវត្ត ដែលបានចុះ MoU | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|
| | | | សង្កាត់ សរុប | សង្កាត់ អនុវត្ត | សាលាបឋម សរុប | សាលាបឋម អនុវត្ត | មណ្ឌល សរុប | មណ្ឌលសុខភាព អនុវត្ត | | |
| ១ | បន្ទាយមានជ័យ | សិរីសោភ័ណ្ឌ | ៧ | ៧ | ២៩ | ១៤ | ៨ | ៨ | ភ្នំស្រីដើម្បីអភិវឌ្ឍន៍ (PSOD) | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) |
| | | ប៉ោយប៉ែត | ៣ | ៣ | ៣៨ | ៦ | ៤ | ៤ | | |
| | សរុប | ២ | ១០ | ១០ | ៦៧ | ២០ | ១២ | ១២ | | |
| ២ | សៀមរាប | សៀមរាប | ១២ | ១២ | ៥២ | ២៤ | ១១ | ១១ | សម្ព័ន្ធសុខភាពកុមារនិងសុខភាពបន្តពូជ (RACHA) | |
| | សរុប | ១ | ១២ | ១២ | ៥២ | ២៤ | ១១ | ១១ | | |
| ៣ | បាត់ដំបង | បាត់ដំបង | ១០ | ១០ | ៣៦ | ២០ | ៧ | ៧ | អង្គការអមរា (Amara) | |
| | សរុប | ១ | ១០ | ១០ | ៣៦ | ២០ | ៧ | ៧ | | |
| ៤ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | ៤ | ៤ | ៨ | ៨ | ២ | ២ | អង្គការស្តារកម្ពុជា (Star Kampuchea) | |
| | សរុប | ១ | ៤ | ៤ | ៨ | ៨ | ២ | ២ | | |
| ៥ | កណ្តាល | តាខ្មៅ | ១០ | ១០ | ២៦ | ២៤ | ៥ | ៥ | វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ (API) | |
| | សរុប | ១ | ១០ | ១០ | ២៦ | ២៤ | ៥ | ៥ | | |
| ៦ | កំពត | កំពត | ៥ | ៥ | ១២ | ១២ | ៣ | ៣ | ភាពជាដៃគូសង្គមស៊ីវិលកម្ពុជា(CCSP) | |
| | សរុប | ១ | ៥ | ៥ | ១២ | ១២ | ៣ | ៣ | | |
| ៧ | រាជធានីភ្នំពេញ | ច្បារអំពៅ | ៨ | ៨ | ២០ | ២០ | ៨ | ៨ | អង្គការដៃគូ ក្រុមប្រឹក្សាយុវជនកម្ពុជា Youth Council of Cambodia (YCC) | |
| | | ព្រែកព្នៅ | ៥ | ៥ | ១៣ | ១៣ | ៥ | ៥ | | |
| | សរុប | ២ | ១៣ | ១៣ | ៣៣ | ៣៣ | ១៣ | ១៣ | | |
| | សរុបរួម | ៩ | ៦៤ | ៦៤ | ២២០ | ១៤១ | ៥៣ | ៥៣ | ៧ អង្គការដៃគូអនុវត្ត | |

| គោលដៅអនុវត្តគណនេយ្យភាពសង្គមនៅសេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ | | | | | |
|---|---|---|---|---|---|
| ១ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | អង្គការស្តារកម្ពុជា (Star Kampuchea) | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ **(USAID)** |
| ២ | បាត់ដំបង | បាត់ដំបង | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | អង្គការអមរា (Amara) | |
| ៣ | កំពត | កំពត | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | ភាពជាដៃគូសង្គមស៊ីវិលកម្ពុជា(CCSP) | |
| ៤ | បន្ទាយមានជ័យ | សិរីសោភ័ណ្ឌ | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | ភ្នំស្រីដើម្បីអភិវឌ្ឍន៍ (PSOD) | |
| ៥ | | ប៉ោយប៉ែត | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | | |
| ៦ | សៀមរាប | សៀមរាប | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | សម្ព័ន្ធសុខភាពកុមារនិងសុខភាពបន្តពូជ (RACHA) | |
| ៧ | កណ្តាល | តាខ្មៅ | គណនេយ្យភាពសង្គមរដ្ឋបាលក្រុង | វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ (API) | |
| ៨ | រាជធានីភ្នំពេញ | ច្បារអំពៅ | គណនេយ្យភាពសង្គមរដ្ឋបាលខណ្ឌ | អង្គការដៃគូ ក្រុមប្រឹក្សាយុវជនកម្ពុជា Youth Council of Cambodia (YCC) | |
| ៩ | | ព្រែកព្នៅ | គណនេយ្យភាពសង្គមរដ្ឋបាលខណ្ឌ | | |

*__បញ្ជាក់៖__ តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ **២០២៣** ខាងលើនេះអាចនឹងមានការប្រែប្រួលក្នុងករណីមានការធ្វើបច្ចុប្បន្នភាពតំបន់គោលដៅអនុវត្ត ដោយស្របតាមការពិភាក្សានិងឯកភាពគ្នារវាងភាគីទាំងពីរ។*

## ជូនភ្ជាប់ឧបសម្ព័ន្ធទី ២៖

# ផែនការថវិកាសម្រាប់អនុវត្តសកម្មភាពប្រចាំឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៣

## ដែលកំណត់ក្នុងអនុស្សរណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គការអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)

| ល.រ | សមាសភាគ | ២០២២-២០២៣ (USD) | ២០២២ (USD) | ២០២៣ (USD) |
|---|---|---|---|---|
| ១ | សមាសភាគទី១៖ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា | $348,608.00 | $174,499.00 | $174,109.00 |
| ២ | សមាសភាគទី២៖ ការត្រួតពិនិត្យ តាមដានដោយប្រជាពលរដ្ឋ | $638,767.00 | $319,381.00 | $319,386.00 |
| ៣ | សមាសភាគទី៣៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម | $49,330.00 | $23,444.00 | $25,886.00 |
| ៤ | សមាសភាគទី៤៖ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង | $45,400.00 | $22,700.00 | $22,700.00 |
| ៥ | សមាសភាគទី៥ ៖ ការគ្រប់គ្រង ត្រួតពិនិត្យតាមដាន និងវាយតម្លៃ | $90,650.00 | $47,325.00 | $43,325.00 |
| ៦ | ចំណាយផ្សេងៗ (សម្ភារៈផ្សព្វផ្សាយ និងឧបករណ៍បច្ចេកវិទ្យាគណនេយ្យភាពសង្គម) | $25,000.00 | $12,500.00 | $12,500.00 |
| | **ថវិកាគ្រោងចំណាយសរុបរួម** | **$1,179,755.00** | **$599,849.00** | **$597,906.00** |

*__បញ្ជាក់៖__ ថវិកាគ្រោងប្រចាំឆ្នាំសម្រាប់អនុវត្តឆ្នាំ ២០២២ និង ២០២៣ ខាងលើអាចនឹងមានការផ្លាស់ប្តូរក្នុងករណីចាំបាច់ ដោយស្របតាមការពិភាក្សា និងឯកភាពរវាងភាគីទាំងពីរ*

# ជូនភ្ជាប់ឧបសម្ព័ន្ធទី ៣៖

## ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០២២

| លរ | សកម្មភាព | គោលដៅ | ចំណូនថវិកា | | ប្រភពថវិកា | ស្ថាប័នប្រតិបត្តិ | អង្គការដៃគូ | 2022 | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | 2022 | | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| សមាសភាគទី១ ៖ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា | | | $174,499 | $174,499 | | | | | | | | | | | | | | | |
| 1 | ការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ បាត់ដំបង និងខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅ | $174,499 | $174,499 | USAID | FHI 360 | NGO partner | x | x | x | | | | | | | | | |
| សមាសភាគទី២ ៖ ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ | | | $319,381 | $319,381 | | | | | | | | | | | | | | | |
| 1 | រៀបចំកិច្ចប្រជុំដាក់ពិន្ទុ និងកិច្ចប្រជុំរួម | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ បាត់ដំបង និងខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅ | $319,381 | $319,381 | USAID | FHI 360 | NGO partner | | | | x | x | x | x | | | | | |
| សមាសភាគទី៣ ៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម | | | $23,444 | $23,444 | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | ការផ្សព្វផ្សាយផែនការ Joint Accountability Action Plan (JAAP) | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ បាត់ដំបង និងខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅ | **$8,806** | $8,806 | USAID | FHI 360 | NGO partner | | | | | | | | x | x | x | | |
| 2 | កិច្ចប្រជុំគណៈកម្មាធិកា JAAP | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ បាត់ដំបង និងខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅ | **$14,638** | $14,638 | USAID | FHI 360 | NGO partner | | | | | | | | x | x | x | x | x |
| **សមាសភាគទី៤ ការបណ្តុះបណ្តាល អភិវឌ្ឍន៍សមត្ថភាព និងការទំនាក់ទំនង** | | | **$22,700** | **$22,700** | | | | | | | | | | | | | | | |
| 1 | វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិកអង្គការដៃគូ | ខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅនៃរាជធានីភ្នំពេញ | **$6,000** | $6,000 | USAID | FHI 360 | FHI 360 | x | | | | | | | | | | | |
| 2 | វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសង្គម | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ បាត់ដំបង និងខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅ | **$16,700** | $16,700 | USAID | FHI 360 | NGO partner | x | | x | | | | x | | | | | |
| **សមាសភាគទី៥ ៖ ការគ្រប់គ្រងគម្រោង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | | | **$47,325** | **$47,325** | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | មន្ត្រីគម្រោងត្រួតពិនិត្យ ការអនុវត្តរបស់អង្គការដៃគូ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ បាត់ដំបង និងខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅ | **$18,800** | $18,800 | USAID | FHI 360 | FHI 360 | x | x | x | x | x | x | x | x | x | x | x | x |
| 2 | អង្គការដៃគូត្រួតពិនិត្យ និងបង្ហាត់បង្ហាញអ្នកសម្របសម្រួលគណនេយ្យភាពសង្គម | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ បាត់ដំបង និងខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅ | **$28,525** | $28,525 | USAID | FHI 360 | NGO partner | x | x | x | x | x | x | x | x | x | x | x | x |
| **សមាសភាគទី៦ ៖ ចំណាយផ្សេងៗ** | | | **$12,500** | **$12,500** | | | | | | | | | | | | | | | |
| 1 | ចំណាយផ្សេងៗ (សម្ភារៈផ្សព្វផ្សាយ និងឧបករណ៍បច្ចេកវិទ្យាគណនេយ្យភាពសង្គម) | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ បាត់ដំបង និងខ័ណ្ឌច្បារអំពៅ និងព្រែកព្នៅ | **$12,500** | $12,500 | USAID | FHI 360 | NGO partner | x | x | x | | | | | x | x | x | | |
| **សរុបរួម** | | | **$599,849** | **$599,849** | | | | | | | | | | | | | | | |

ឧបសម្ព័ន្ធទី ៤÷

## មាតិកា

## របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម

១. សេចក្តីផ្តើម

២. វឌ្ឍនៈភាព នៃការអនុវត្ត

៣. បញ្ហាប្រឈម និងដំណោះស្រាយ

៤ ស្ថានភាពហិរញ្ញវត្ថុ

៥. សំណូមពរ និងអនុសាសន៍

៦. សេចក្តីសន្និដ្ឋាន